រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សៀវភៅណែនាំ

# ស្តីពី

# ពន្ធកាត់ទុកលើនិវាសនជន និង អនិវាសនជន

ឆ្នាំ ២០១៣

រៀបចំ និង បោះពុម្ពផ្សាយដោយ
អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រក្សាសិទ្ធិគ្រប់បែបយ៉ាង

| មាតិកា | ទំព័រ |
|---|---|
| ពន្ធកាត់ទុកគឺជាអ្វី? | ១ |
| តើនរណាត្រូវប្រមូលពន្ធកាត់ទុក? | ១ |
| តើការទូទាត់ឲ្យទៅនិវាសនជនប្រភេទណាខ្លះដែលជាប់ពន្ធកាត់ទុក? | ១ |
| តើការទូទាត់ឲ្យទៅអនិវាសនជនប្រភេទណាខ្លះដែលជាប់ពន្ធកាត់ទុក? | ៤ |
| តើការទូទាត់ប្រភេទណាខ្លះដែលមិនជាប់ពន្ធកាត់ទុក? | ៥ |
| តើពន្ធកាត់ទុកត្រូវបានគណនាយ៉ាងដូចម្តេច? | ៦ |
| តើត្រូវដាក់លិខិតប្រកាសពន្ធនិងបង់ពន្ធនៅពេលណា? | ៧ |
| ទោសទណ្ឌ | ៨ |
| សំណួរ | ៩ |
| អាសយដ្ឋានទំនាក់ទំនង | ៩ |

## ពន្ធកាត់ទុកគឺជាអ្វី?

ពន្ធកាត់ទុកគឺជាពន្ធដែលត្រូវបានកាត់ទុកដោយអ្នកជាប់ពន្ធនិវាសនជនលើការទូទាត់មួយចំនួនដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឲ្យទៅអ្នកជាប់ពន្ធនិវាសនជន និងអនិវាសនជន។

## តើនរណាត្រូវប្រមូលពន្ធកាត់ទុក?

អ្នកជាប់ពន្ធនិវាសនជនប្រកបអាជីវកម្មទាំងអស់ត្រូវប្រមូលពន្ធកាត់ទុក។ ពន្ធកាត់ទុកដែលប្រមូលបានត្រូវបង់ទៅឲ្យអគ្គនាយកដ្ឋានពន្ធដារ។

## តើការទូទាត់ប្រភេទណាខ្លះឲ្យទៅនិវាសនជនដែលជាប់ពន្ធកាត់ទុក?

ការទូទាត់ទាំងឡាយខាងក្រោមដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឲ្យទៅនិវាសនជន ដោយអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ត្រូវជាប់ពន្ធកាត់ទុក។

**សេវាកម្មៈ** ប្រាក់ចំណូលដែលរូបវន្តបុគ្គលទទួលបានពីការបំពេញសេវានានារួមមាន ការគ្រប់គ្រង ឬការពិគ្រោះយោបល់ ឬសេវាប្រហាក់ប្រហែល។

សេវាទាំងនេះរួមមានសកម្មភាពសេដ្ឋកិច្ចរបស់រូបវន្តបុគ្គល **ក្រៅតែ**ពីការផលិតនិងការលក់ទំនិញភតិសន្យាការជួលឬការលក់នូវទ្រព្យសម្បត្តិ និងក្រៅពីសកម្មភាពបម្រើការងារដែលជាប់ពន្ធលើប្រាក់បៀវត្ស។

ប្រាក់ចំណូលនេះមានជាអាទិ៍ប្រាក់ចំណូលពីកំរៃជើងសារ ឬជើងសារជំនួញ ប្រាក់ចំណូលពីសកម្មភាពដឹកជញ្ជូនជួសជុល

សាងសង់ គ្រប់គ្រង ឬពិគ្រោះយោបល់ ប្រាក់ចំណូលបានពីសេវាវិទ្យាសាស្ត្របច្ចេកទេស សិល្បៈ ឬការអប់រំ ប្រាក់ចំណូលបានពីសេវាខាងវេជ្ជសាស្ត្រ ទន្តសាស្ត្រ នីតិសាស្ត្រ វិស្វកម្ម ស្ថាបត្យកម្ម ការសិក្សា និងស្រាវជាវគណនេយ្យ។ល។

**សួយសារពីទ្រព្យសកម្មអរូបី៖** សម្រាប់គោលដៅនៃពន្ធកាត់ទុក សួយសារពីទ្រព្យសកម្មអរូបីគឺសំដៅដល់ចំណូលបានមកពីការអនុញ្ញាតឲ្យប្រើប្រាស់សិទ្ធិបោះពុម្ពផ្សាយលក់ស្នាដៃអក្សរសាស្ត្រសិល្បៈវិទ្យាសាស្ត្រ ឬសិទ្ធិប្រហាក់ប្រហែល (ក្នុងនោះមានរាប់បញ្ចូលទាំងសិទ្ធិថតចំលង និងផ្សាយខ្សែអាត់សម្លេងឬវីដេអូ) ចំណេះដឹង ឬចំណេះធ្វើ ឬព័ត៌មានទាក់ទិននឹងបទពិសោធន៍ផ្សេងៗក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្របច្ចេក-ទេស។ល។ ការផ្ទេរសិទ្ធិលើចំណេះ ឬព័ត៌មានដូចមានរៀបរាប់នៅក្នុងកថាខណ្ឌនេះឬការផ្តល់យោបល់ ឬការផ្តល់សេវាទាក់ទិននឹងការអនុវត្ត ឬការប្រើប្រាស់សិទ្ធិដូចមានរៀបរាប់នៅក្នុងកថាខណ្ឌនេះ។

**សួយសារបានមកពីភាគកម្មក្នុងធនធានរ៉ែ៖** សម្រាប់គោលដៅនៃពន្ធកាត់ទុក សួយសារបានមកពីភាគកម្មក្នុងធនធានរ៉ែសំដៅដល់រាល់អត្ថប្រយោជន៍ជាប្រាក់ ឬជាវត្ថុដែលទទួលបានទាក់ទិននឹងភាគកម្មនេះ **ក្រៅតែ**ពីប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធាននេះ និងភាគលាភដែលត្រូវជាប់ពន្ធតាមបទប្បញ្ញត្តិដោយឡែក។

**ចំណូលពីការប្រាក់ (ស្ថាប័នមិនមែនធនាគារ ឬស្ថាប័នសញ្ញ័យធន)៖** ការប្រាក់ដែលអ្នកជាប់ពន្ធនិវាសនជនមិនមែនជាធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ទៅឲ្យរូបវន្តបុគ្គល ឬសហគ្រាស។

**ថ្លៃឈ្នួល៖** សម្រាប់គោលបំណងនៃពន្ធកាត់ទុកថ្លៃឈ្នួលពីការជួលចលនទ្រព្យ ឬអចលនទ្រព្យគឺសំដៅដល់សាច់ប្រាក់ ឬវត្ថុដែលអ្នកជួលបានបង់សម្រាប់ជាថ្នូរនៃការប្រើប្រាស់ចលនទ្រព្យ (ដូចជាបរិក្ខារឧស្សាហកម្មពាណិជ្ជកម្ម បច្ចេកទេស ឬវិទ្យាសាស្ត្រ) ឬអចលនទ្រព្យ (ដូចជាដីធ្លីផ្ទះសម្បែង ឬសំណង់ផ្សេងៗ)។ អចលនទ្រព្យត្រូវមានរួមបញ្ចូលលក្ខណៈទាំងអស់របស់ទ្រព្យបន្ទាប់បន្សំនៃអចលនទ្រព្យនោះ ព្រមទាំងសិទ្ធិអនុវត្តទៅតាមច្បាប់ស្ដីពីកម្មសិទ្ធិដីធ្លី សិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើអចលនទ្រព្យ (ក្នុងករណីទ្រព្យនោះមិនមានការខូចខាត ឬបំផ្លិចបំផ្លាញណាមួយ) និងសិទ្ធិនានាដែលបង្កឲ្យមានការទូទាត់តាមចំនួនកំណត់ ឬមិនកំណត់។

**ចំណូលពីការប្រាក់ (ប្រាក់បញ្ញើមានកាលកំណត់)៖** ការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ទៅឲ្យអ្នកជាប់ពន្ធនិវាសនជន (រូបវន្តបុគ្គល និងនីតិបុគ្គល) ដែលមានគណនីបញ្ញើមានកាលកំណត់។

**ចំណូលពីការប្រាក់ (បញ្ញើសន្សំគ្មានកាលកំណត់)៖** ការប្រាក់ដែលធនាគារ ឬស្ថាប័នសញ្ញ័យធនក្នុងស្រុកបង់ទៅឲ្យរូបវន្តបុគ្គល

និវាសនជនដែលមានប្រាក់បញ្ញើនៅក្នុងគណនីសន្សំគ្មានកាលកំណត់។

## តើការទូទាត់ប្រភេទណាខ្លះឲ្យទៅអនិវាសនជនដែលជាប់ពន្ធកាត់ទុក?

ការទូទាត់ទាំងឡាយខាងក្រោមដែលធ្វើឡើងជាសាច់ប្រាក់ ឬជាវត្ថុឲ្យទៅអនិវាសនជនដោយអ្នកជាប់ពន្ធនិវាសនជនដែលប្រកបអាជីវកម្ម ត្រូវជាប់ពន្ធកាត់ទុក។

- ការទូទាត់ចំពោះសេវាគ្រប់គ្រង និងសេវាបច្ចេកទេសនានា
- ការប្រាក់
- ភាគលាភ
- សួយសារបានមកពីទ្រព្យសកម្មអរូបីដែលបានទូទាត់ទៅឲ្យអនិវាសនជន (សូមមើលទំព័រទី២ "សួយសារបានមកពីទ្រព្យសកម្មអរូបីបានទូទាត់ទៅឲ្យនិវាសនជន")។
- សួយសារបានមកពីភាគកម្មនៅក្នុងធនធានរ៉ែប្រេងកាត ឬឧស្ម័នធម្មជាតិ។ សួយសារនេះសំដៅដល់អត្ថប្រយោជន៍ជាសាច់ប្រាក់ ឬជាវត្ថុដែលទទួលបានទាក់ទិននឹងភាគកម្មទាំងនេះ **ក្រៅតែពី**ប្រាក់ចំណេញបានមកពីអាជីវកម្មលើធនធានទាំងនេះនិងភាគលាភ។
- ថ្លៃឈ្នួលទូទាត់ឲ្យទៅអនិវាសនជន (សូមមើលទំព័រទី៣ "ថ្លៃឈ្នួល")។

## តើការទូទាត់ប្រភេទណាខ្លះដែលត្រូវបានអនុគ្រោះលើកលែងពន្ធកាត់ទុក?

ការទូទាត់ពណ៌នាខាងក្រោមត្រូវបានអនុគ្រោះលើកលែងពន្ធកាត់ទុកៈ

- ការប្រាក់ដែលបង់ឲ្យទៅធនាគារ ឬស្ថាប័នសញ្ជ័យធន ឬស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក
- ការទូទាត់ទៅឲ្យរាជរដ្ឋាភិបាល ឬស្ថាប័ននៃរាជរដ្ឋាភិបាលនូវសួយសារ ឬប្រាក់ថ្លៃឈ្នួលលើចលនទ្រព្យឬអចលនទ្រព្យ (ក្នុងនោះមានរួមបញ្ចូលផងដែរនូវប្រាក់ទូទាត់លើការធ្វើអាជីវកម្មកំពង់ផែ ដីសម្បទានសេដ្ឋកិច្ច និងភាស៊ីផ្សារ ។ល។) លុះត្រាតែការទូទាត់នេះត្រូវទាក់ទិននឹងចលនទ្រព្យ ឬអចលនទ្រព្យដែលបានកត់ត្រាជាទ្រព្យសម្បត្តិរដ្ឋនៅក្នុងបញ្ជីសារពើភ័ណ្ឌគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយប្រាក់ទូទាត់ត្រូវមានការបញ្ជាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុថាជាចំណូលមិនមែនសារពើពន្ធបង់ចូលថវិការដ្ឋ។
- ការទូទាត់នូវប្រាក់ចំណូលដែលពន្ធលើប្រាក់បៀវត្ស ឬពន្ធលើអត្ថប្រយោជន៍បន្ថែមត្រូវបានកាត់ទុករួចរាល់។
- ការទូទាត់នូវការប្រាក់ដោយរាជរដ្ឋាភិបាល ឬ ស្ថាប័នរាជរដ្ឋាភិបាលទៅឲ្យបុគ្គលអនិវាសនជនចំពោះប្រាក់កម្ចីដែលរាជរដ្ឋាភិបាលកម្ពុជា ឬរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលស្គាល់ និងយល់ព្រម។
- ការទូទាត់នូវប្រាក់ចំណូលពីការបំពេញសេវានានារួមទាំងការគ្រប់គ្រង ឬការពិគ្រោះយោបល់ឬសេវាប្រហាក់ប្រហែលរបស់សហគ្រាសនីតិបុគ្គលដែលបានចុះបញ្ជីជាសហគ្រាស

ជាប់ពន្ធតាមរបបពិត។ ប៉ុន្តែទឹកប្រាក់នោះត្រូវតែកត់ត្រាក្នុងវិក្កយបត្រដែលចេញដោយអ្នកទទួលប្រាក់និងត្រូវបានកត់ត្រាច្បាស់លាស់ហើយមានព័ត៌មានគ្រប់គ្រាន់ដូចមានចែងក្នុងប្រកាសលេខ ៣៩១ ប្រក.សហវ.ពដ និងប្រកាសលេខ ៣៩២ ប្រក.សហវ.ពដចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## តើពន្ធកាត់ទុកត្រូវគណនាយ៉ាងដូចម្តេច?

ពន្ធកាត់ទុកត្រូវបានគណនាដោយការគុណមូលដ្ឋានគិតពន្ធនឹងអត្រាពន្ធដែលអនុវត្ត។

**មូលដ្ឋានគិតពន្ធ៖ ពន្ធកាត់ទុកត្រូវគណនាលើចំនួនទឹកប្រាក់ដុលដែលត្រូវទូទាត់ឲ្យបុគ្គលណាមួយ។ ចំពោះការទូទាត់ប្រាក់ឲ្យអនិវាសនជន ដែលទាក់ទិនដល់ការផ្គត់ផ្គង់សម្ភារៈបរិក្ខារផង និងសេវាផង ដូចជានៅក្នុងការទូទាត់ចំណាយទិញម៉ាស៊ីនពីក្រៅប្រទេសដែលរួមមានថ្លៃទិញម៉ាស៊ីន និងថ្លៃសេវាផ្គុំដំឡើងដោយអ្នកបច្ចេកទេសជាបុគ្គលអនិវាសនជនផ្តល់ដោយអ្នកលក់ (សម្រាប់ដំណើរការដើមដំបូងនៃម៉ាស៊ីន) មូលដ្ឋានសម្រាប់គិតពន្ធកាត់ទុកគឺជាចំណែកប្រាក់ដែលទាក់ទិននឹងសេវាផ្គុំដំឡើងនេះតែប៉ុណ្ណោះ។**

ដរាបណាការទូទាត់មិនទាន់ចាត់ជាចំណាយ កាតព្វកិច្ចកាត់ទុកពន្ធក៏នឹងមិនកើតមានឡើងដែរ។ ប៉ុន្តែការទូទាត់នេះត្រូវបានចាត់ទុកថាបានធ្វើឡើង ប្រសិនបើការទូទាត់នេះត្រូវបានកាត់កងជា

ចំណាយអាជីវកម្ម ហើយភ្នាក់ងារកាត់ទុកត្រូវបង់ពន្ធកាត់ទុក ក្នុងនាមអ្នកទទួល។

**តារាងអត្រាពន្ធ៖**

| ប្រភេទការទូទាត់ | អត្រាពន្ធ |
|---|---|
| 1. អ្នកទទួលនិវាសនជន ចំពោះការបំពេញសេវានានាស្ទួយសារនិងការប្រាក់ទូទាត់ដោយអ្នកជាប់ពន្ធ ក្រៅពីធនាគារ ឬស្ថាប័នសញ្ជ័យធន | ១៥% |
| 2. អ្នកទទួលនិវាសនជន ចំពោះការជួលចលនទ្រព្យ ឬអចលនទ្រព្យ | ១០% |
| 3. អ្នកទទួលនិវាសនជនចំពោះការប្រាក់ទូទាត់ដោយធនាគារឬស្ថាប័នសញ្ជ័យធនសម្រាប់គណនីបញ្ញើមានកាលកំណត់ | ៦% |
| 4. អ្នកទទួលនិវាសនជនចំពោះការប្រាក់ទូទាត់សម្រាប់គណនីសន្សំគ្មានកាលកំណត់ | ៤% |
| 5. អ្នកទទួលអនិវាសនជនចំពោះការទូទាត់គ្រប់ប្រភេទទាំងអស់ | ១៤% |

## តើត្រូវដាក់លិខិតប្រកាសពន្ធ និងបង់ពន្ធនៅពេលណា?

ភ្នាក់ងារកាត់ទុកមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់ពីខែដែលបានធ្វើការកាត់ទុក។

ភ្នាក់ងារកាត់ទុកសំដៅដល់បុគ្គល ឬនីតិបុគ្គលដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានតម្រូវឲ្យធ្វើការកាត់ទុក និងបង់ពន្ធចូលថវិការដ្ឋក្នុងនាមអ្នកទទួល។

លិខិតប្រកាសពន្ធត្រូវដាក់ទៅការិយាល័យអ្នកជាប់ពន្ធធំ (សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សាខាក្រុមហ៊ុមបរទេស ឬក្រុមហ៊ុនពហុជាតិ ឬសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី ១.០០០ លានរៀល ឡើងទៅ) ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលអាជីវកម្មនោះតាំងនៅ (សម្រាប់អ្នកជាប់ពន្ធដទៃទៀត)។

## ទោសទណ្ឌ

ភ្នាក់ងារកាត់ទុកត្រូវទទួលខុសត្រូវយ៉ាងពេញលេញ និងរួមគ្នាជាមួយនឹងបុគ្គលជាមុខសញ្ញា ត្រូវកាត់ទុកប្រាក់ពន្ធចំពោះប្រាក់ពន្ធដែលត្រូវកាត់ទុកនិងបង់ជូនរដ្ឋបាលសារពើពន្ធ។ ក្នុងករណីដែលភ្នាក់ងារកាត់ទុកមិនបានបង់ឲ្យបានត្រឹមត្រូវនូវប្រាក់ពន្ធដែលច្បាប់បានតម្រូវឲ្យខ្លួនធ្វើការកាត់ទុកនិងបង់ជូនរដ្ឋបាលសារពើពន្ធ ភ្នាក់ងារកាត់ទុកនឹងត្រូវទទួលរងនូវការកំណត់ពន្ធជាឯកតោភាគី ឬការកំណត់ពន្ធឡើងវិញព្រមទាំងប្រាក់ពិន័យផ្សេងទៀតដូចគ្នានឹងបំណុលពន្ធរបស់ភ្នាក់ងារកាត់ទុកខ្លួនឯងផ្ទាល់ផងដែរ។ ភ្នាក់ងារកាត់ទុកក៏ត្រូវទទួលរងនូវទោសទណ្ឌផ្សេងៗទៀតដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ។

## សំណួរ

ប្រសិនបើលោកអ្នកមានចម្ងល់ឬសំណួរផ្សេងៗ ដែលពុំទាន់ឆ្លើយនៅក្នុងឯកសារបោះពុម្ពផ្សាយនេះសូមចូលទៅមើលជំពូកទី៨ នៃប្រកាសស្តីពីពន្ធលើប្រាក់ចំណេញ (ប្រកាសលេខ១០៥៩ប្រក.សហវ.ពដចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) ឬសូមទាក់ទងមកកាន់ការិយាល័យរដ្ឋបាលសារពើពន្ធណាមួយដែលក្រុមហ៊ុនបានចុះបញ្ជី។

## អាសយដ្ឋានទំនាក់ទំនង

### អគ្គនាយកដ្ឋានពន្ធដារ

ឡូត៍លេខ ៥២២-៥២៤ កែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទ៖ (៨៥៥) ២៣ ៨៨៦ ៧០៨

សារអេឡិចត្រូនិក៖ info@tax.gov.kh

### នាយកដ្ឋាន សេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ

សារអេឡិចត្រូនិក៖ dtsta@tax.gov.kh

### នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ

សារអេឡិចត្រូនិក៖ dlls@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ

សារអេឡិចត្រូនិក៖ dlt@tax.gov.kh

## សាខាពន្ធដារ ខណ្ឌឬស្សីកែវ

ផ្ទះលេខ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ russeykeo@tax.gov.kh

## សាខាពន្ធដារ ខណ្ឌដូនពេញ

ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្តាលទី២
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ daunpenh@tax.gov.kh

## សាខាពន្ធដារ ខណ្ឌ៧មករា

ផ្ទះលេខ២៥បេ ផ្លូវសម្តេចប៉ាន(២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ 7makara@tax.gov.kh

## សាខាពន្ធដារ ខណ្ឌមានជ័យ

អគារលេខ៣៨សេ ផ្លូវ៣៦១កែង៦៤២ សង្កាត់ច្បារអំពៅ១
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ meanchey@tax.gov.kh

## សាខាពន្ធដារ ខណ្ឌចំការមន

ផ្ទះលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន
រាជធានីភ្នំពេញ
សារអេឡិចត្រូនិក៖ chamkarmorn@tax.gov.kh

## សាខាពន្ធដារ ខណ្ឌទួលគោក

ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ tuolkork@tax.gov.kh

## សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤ ផ្លូវលេខ២០០៧ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

សារអេឡិចត្រូនិក៖ dangkor@tax.gov.kh

## សាខាពន្ធដារ ខេត្តកណ្ដាល

ផ្ទះលេខ១០៣ ផ្លូវលេខ១០៨ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

សារអេឡិចត្រូនិក៖ kandal@tax.gov.kh

## សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទលេខ៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម

សារអេឡិចត្រូនិក៖ kampongcham@tax.gov.kh

## សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

សារអេឡិចត្រូនិក៖ battambang@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រៃវែង**

ភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

សារអេឡិចត្រូនិក៖ preyveng@tax.gov.kh

**សាខាពន្ធដារ ខេត្តសៀមរាប**

ផ្លូវជាតិលេខ៦ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

សារអេឡិចត្រូនិក៖ siamreap@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ធំ**

ផ្លូវលេខ៦ ភូមិត្រឡាំងលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ

សារអេឡិចត្រូនិក៖ kampong_thom@tax.gov.kh

**សាខាពន្ធដារ ខេត្តតាកែវ**

ផ្លូវលេខ៣ ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ

សារអេឡិចត្រូនិក៖ takeo@tax.gov.kh

**សាខាពន្ធដារ ខេត្តស្វាយរៀង**

ផ្លូវភូមិរោងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង

សារអេឡិចត្រូនិក៖ svayrieng@tax.gov.kh

**សាខាពន្ធដារ ខេត្តពោធិ៍សាត់**

ផ្លូវជាតិលេខ៥ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់

សារអេឡិចត្រូនិកៈ pursat@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង**

ភូមិឃ្លាំងប្រាក់ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

សារអេឡិចត្រូនិកៈ kampongchhnang@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពង់ស្ពឺ**

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

សារអេឡិចត្រូនិកៈ kampongspeu@tax.gov.kh

**សាខាពន្ធដារ ខេត្តកំពត**

ភូមិ១ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត

សារអេឡិចត្រូនិកៈ kampot@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះសីហនុ**

ផ្លូវ២៨មិថុនា សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

សារអេឡិចត្រូនិៈ preahsihanouk@tax.gov.kh

**សាខាពន្ធដារ ខេត្តកោះកុង**

ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង

សារអេឡិចត្រូនិកៈ kohkong@tax.gov.kh

**សាខាពន្ធដារ ខេត្តព្រះវិហារ**

ភូមិកណ្ដាល សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ

សារអេឡិចត្រូនិក៖ preahvihear@tax.gov.kh

**សាខាពន្ធដារ ខេត្តក្រចេះ**

ផ្ទះលេខ៧៣ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ

សារអេឡិចត្រូនិក៖ kratie@tax.gov.kh

**សាខាពន្ធដារ ខេត្តរតនៈគិរី**

ផ្លូវភូមិអូរកន្សែង សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនៈគិរី

សារអេឡិចត្រូនិក៖ ratanakiri@tax.gov.kh

**សាខាពន្ធដារ ខេត្តមណ្ឌលគិរី**

ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី

សារអេឡិចត្រូនិក៖ mondulkiri@tax.gov.kh

**សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ**

ប្លុកU ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ

សារអេឡិចត្រូនិក៖ banteaymeanchey@tax.gov.kh

**សាខាពន្ធដារ ខេត្តស្ទឹងត្រែង**

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង

សារអេឡិចត្រូនិក៖ stoengtreng@tax.gov.kh

**សាខាពន្ធដារ ខេត្តកែប**

ផ្លូវ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប

សារអេឡិចត្រូនិក៖ kep@tax.gov.kh

**សាខាពន្ធដារ ខេត្តប៉ៃលិន**

ភូមិបឱនាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន

សារអេឡិចត្រូនិក៖ pailin@tax.gov.kh

**សាខាពន្ធដារ ខេត្តឧត្តរមានជ័យ**

ភូមិឈ្យូក សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ

សារអេឡិចត្រូនិក៖ odormeanchey@tax.gov.kh